# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចព្រមព្រៀង
## រវាង តំណាងបុគ្គលិក សណ្ឋាគារ សុខាអង្គរ
## និង និយោជកនៃ សណ្ឋាគារ សុខាអង្គរ

អនុស្សរណៈនៃការយោគយល់នេះត្រូវបានធ្វើឡើងនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២២ រវាងបុគ្គលិកនៃសណ្ឋាគារ សុខាអង្គរ (ពីនេះតទៅហៅថា "តំណាងបុគ្គលិក") និងតំណាងសណ្ឋាគារ សុខា អង្គរ (ពីនេះតទៅហៅថា "និយោជក")។

ដោយសារស្ថានភាពវិបត្តិជំងឺ Covid-19 នៅលើពិភពលោកនៅតែពុំទាន់ថមថយ ធ្វើអោយប្រក្រតីភាពនៃដំណើរការសេដ្ឋកិច្ច និងពាណិជ្ជកម្មគ្រប់វិស័យនៅលើពិភពលោក រួមទាំងប្រទេសកម្ពុជាយើងផងនៅតែទទួលរងនូវបញ្ហាប្រឈមដ៏ធ្ងន់ធ្ងរ ជាពិសេសលើវិស័យទេសចរណ៍ និងបដិសណ្ឋាកិច្ច។ អាស្រ័យហេតុនេះយើងខ្ញុំបានសម្រេចចិត្តបន្តផ្អាកសកម្មភាពអាជីវកម្មពេញលេញរបស់ សណ្ឋាគារ សុខាអង្គរ ជាបណ្តោះអាសន្ន រយៈពេលសាមសិបមួយថ្ងៃបន្តទៀត(៣០)ថ្ងៃបន្តទៀត ដោយគិតចាប់ពីថ្ងៃទី០២ ខែមករា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣ ។ ហេតុនេះ ដើម្បីសម្រាលនូវបញ្ហាប្រឈមដ៏ធ្ងន់ធ្ងរនៅចំពោះមុខនេះ និយោជក និងតំណាងបុគ្គលិក បានចរចារ និងព្រមព្រាងគ្នាដាក់ឲ្យបុគ្គលិកចំនួន ០៥នាក់ ស្រី ១នាក់ បន្តឈប់សម្រាកពីការងារដោយឥតប្រាក់ឈ្នួល រយៈពេលសាមសិបមួយថ្ងៃ(៣០)ថ្ងៃទៀត គិតចាប់ពីថ្ងៃទី០២ ខែមករា ឆ្នាំ២០២៣ ដល់ ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣។

ភាគីទាំងពីរបានព្រមព្រៀងគ្នា លើលក្ខខណ្ឌដូចខាងក្រោម៖

- និយោជិតដែលត្រូវបានដាក់ឲ្យឈប់សម្រាកពីការងាររយៈពេលសាមសិបមួយថ្ងៃ(៣០)ថ្ងៃ នឹងមិនទទួលបានប្រាក់ឈ្នួល និងប្រាក់ធានានុគ្រោះទេ នៅក្នុងអំឡុងពេលនៃការឈប់សម្រាកនេះ។
- និយោជក នឹងរក្សាទុកក្នុងកម្មករនិយោជិតចំនួនអប្បបរមា ទៅតាមតម្រូវការជាក់ស្តែងនៃផ្នែកនិមួយៗ ដើម្បីបំពេញការងារក្នុងកំឡុងពេលផ្អាកដំណើរការអាជីវកម្ម។

សូមបញ្ជាក់ថា ចំណុចដូចដែលបានរៀបរាប់ខាងលើនេះ គឺសម្រាប់ការអនុវត្តរយៈពេលម្ភៃសាមសិបមួយថ្ងៃ(៣០)ថ្ងៃ គិតចាប់ពីថ្ងៃទី០២ ខែមករា ឆ្នាំ២០២៣ ដល់ ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣។ ក្រុមហ៊ុននឹងធ្វើការជូនដំណឹងជាថ្មី ប្រសិនបើស្ថានការណ៍មានការប្រែប្រួល ហើយគូភាគីនឹងពិនិត្យមើលអនុស្សរណៈនៃការយោគយល់នេះ ពីខាងក្រោមនេះ៖

សណ្ឋាគារសុខាអង្គរ
SOKHA ANGKOR HOTEL
BRANCH OF SOKHA HOTEL CO. LTD.

| ហត្ថលេខាភាគីតំណាងនិយោជក | ហត្ថលេខាភាគីតំណាងនិយោជិត |
|---|---|
| ប៊ុន ម៉េង | យន់ គាន់ Kean |
| | ជូន វណ្ណសល់ ______ |

សាខាក្រុមហ៊ុន សុខា ហូតែល
សណ្ឋាគារសុខាអង្គរ
SOKHA ANGKOR HOTEL
BRANCH OF SOKHA HOTEL CO., LTD.